ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាឧទ្ធរណ៍

# តាងនាមប្រជារាស្ត្រខ្មែរ

សំណុំរឿងព្រហ្មទណ្ឌ
លេខ ១០៦៧/១១-១២-១៣

សាលដីកា
លេខ ៤៣ ក្រ'''យ''ចុះ
ថ្ងៃទី ០៥-៩-២០១៤

សាលាឧទ្ធរណ៍ភ្នំពេញ
បង្កើតឡើងតាមច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពរបស់សាលាជម្រះក្តី ដែលប្រកាសឲ្យប្រើតាមព្រះរាជក្រមលេខ នស/រកម/០៧១៤/០១៥ ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៤ បានបើកសវនាការជាសាធារណៈ នៅសាលាឧទ្ធរណ៍ នាថ្ងៃទី ២៧-៨-២០១៤ ដែលមានសមាសភាពដូចតទៅៈ

**សមាសភាពក្រុមប្រឹក្សាជំនុំជម្រះ**

លោក [redacted] ប្រធាន
លោក [redacted] ចៅក្រមប្រឹក្សា
លោក [redacted] ចៅក្រមប្រឹក្សា

**តំណាងមហាអយ្យការ**

ឯកឧត្តម [redacted]

**ក្រឡាបញ្ជីសវនាការ**

លោក [redacted]

បានបើកសវនាការជំនុំជម្រះសំណុំរឿងព្រហ្មទណ្ឌដែលមានលេខ ១០៦៧ចុះថ្ងៃទី ១១-១២-២០១៣ រវាង ៖

-ជនជាប់ចោទឈ្មោះ

-[redacted] **ហ៊ីម** ភេទប្រុស អាយុ៣៩ឆ្នាំ ជាតិខ្មែរ មុខរបរ ពាណិជ្ជករ កើតនៅភូមិ-[redacted] មានទីលំនៅសព្វថ្ងៃផ្ទះ [redacted] ឪពុកឈ្មោះ [redacted] ''ស''ម្តាយឈ្មោះ [redacted] ''ស'' ប្រពន្ធឈ្មោះ [redacted] មានកូនចំនួន០២នាក់ (ឃុំខ្លួន)។ មានមេធាវីការពារសិទ្ធិឱ្យឈ្មោះ [redacted] **ឿឿង**, [redacted] **សេដ្ឋា**។

**ត្រូវជាប់ចោទពីបទ** ៖ គំរាមកំហែងថានឹងសម្លាប់ដោយមានបញ្ជាឱ្យបំពេញលក្ខខណ្ឌអ្វីមួយៗ

ប្រព្រឹត្តនៅរាជធានីភ្នំពេញ កាលពីថ្ងៃទី ៣០-៩-២០១១ និងថ្ងៃទី ០១-១០-២០១១ តាមបញ្ញត្តិមាត្រា ២៣៤ នៃក្រមព្រហ្មទណ្ឌ។

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ភេទស្រី អាយុ៤២ឆ្នាំ ជាតិខ្មែរ មានទីលំនៅផ្ទះ [redacted]។

## រឿងរ៉ាវហេតុមានដូចតទៅ

កាលពីថ្ងៃទី ២៥-៩-២០១១ ឈ្មោះ [redacted] ហ៊ីម និងប្រពន្ធឈ្មោះ [redacted] ហៀង បានមកពឹងពាក់ឈ្មោះ [redacted] សុខា ឱ្យជួយរកខ្ចីប្រាក់គេចំនួន ១០០ ០០០$ (ដប់ម៉ឺនដុល្លាអាមេរិក) ដោយដាក់ប័ណ្ណសំគាល់សិទ្ធិកាន់កាប់អចលនវត្ថុ។ ពេលនោះឈ្មោះ [redacted] សុខា បាននាំទៅជួបឈ្មោះ [redacted] រតនា ដើម្បីខ្ចីប្រាក់ ដោយបានធ្វើកិច្ចសន្យាទទួលប្រាក់ចុះថ្ងៃ ២៥-៩-២០១១ រួចប្រគល់ប្រាក់ចំនួន ១២ ០០០$ (មួយម៉ឺនពីរពាន់ដុល្លាអាមេរិក) ឱ្យទៅឈ្មោះ [redacted] ហ៊ីម និងប្រពន្ធឈ្មោះ [redacted] ហៀង ដោយបានបញ្ជាក់ថា ឱ្យពួកគេបំពេញឯកសារនៅសុរិយោដីរួចរាល់ ទើបប្រគល់ប្រាក់នៅសល់ចំនួន ៨៨ ០០០$ បន្ថែមទៀត។ ឈ្មោះ [redacted] ហ៊ីម និងប្រពន្ធមិនបានបំពេញចុះបន្ទុកនៅសុរិយោដីផង ស្រាប់តែឈ្មោះ [redacted] ហ៊ីម បានគំរាមថា និងបាញ់សម្លាប់ជនរងគ្រោះចោលចំនួន ០២ដង គឺលើកទី១ នៅថ្ងៃទី ៣០-៩-២០១១ តាមប្រព័ន្ធទូរស័ព្ទ និងលើកទី២ នៅថ្ងៃទី ០១-១០-២០១១ នៅចំណុចហាងមង្គលបូរី "ក្បែរក្រសួងការពារជាតិ" រាជធានីភ្នំពេញ ប្រសិនបើមិនប្រគល់ប្រាក់ដែលនៅសល់ឱ្យខ្លួននោះទេ។

-បានឃើញសាលក្រមព្រហ្មទណ្ឌលេខ ២៤ "ម" ចុះថ្ងៃទី ១៤-៦-២០១៣ របស់សាលាដំបូងរាជធានីភ្នំពេញ ដែលមានខ្លឹមសារសម្រេចដូចខាងក្រោម៖

១-ផ្តន្ទាទោសឈ្មោះ [redacted] ហ៊ីម ភេទប្រុស អាយុ៣៩ឆ្នាំ ដាក់ពន្ធនាគារកំណត់ ០១"មួយ"ឆ្នាំ និងពិន័យជាប្រាក់ចំនួន ២ ០០០ ០០០៛ "ពីរលាន" រៀល។

ពីបទ: គំរាមកំហែងថានឹងសម្លាប់ ដោយមានបញ្ជាឱ្យបំពេញលក្ខខណ្ឌអ្វីមួយ ប្រព្រឹត្តនៅរាជធានីភ្នំពេញ កាលពីថ្ងៃទី ៣០-៩-២០១១ និងថ្ងៃទី ០១-១០-២០១១ តាមបញ្ញត្តិមាត្រា ២៣៤ នៃក្រមព្រហ្មទណ្ឌ។

២-បង្គាប់ឱ្យឈ្មោះ [redacted] ហ៊ីម សងសំណងជម្ងឺចិត្តចំនួន ៤០ ០០០ ០០០៛ (សែសិបលាន) រៀល ឱ្យទៅជនរងគ្រោះ និងជាដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted]។

-សាលក្រមនេះជំនុំជម្រះជាសាធារណៈ នៅថ្ងៃទី ០៧-៦-២០១៣ ចំពោះមុខជនជាប់ចោទ មេធាវីការពារឱ្យជនជាប់ចោទ, មេធាវីការពារឱ្យដើមបណ្តឹងរដ្ឋប្បវេណី និងប្រកាសជាសាធារណៈនៅថ្ងៃទី ១៤-៦-២០១៣។

រក្សាសិទ្ធិប្តឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់។

-បានឃើញបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី ១២-៧-២០១៣ របស់ឈ្មោះ [redacted] **ហ៊ីម** សុំប្តឹងឧទ្ធរណ៍នឹងសាលក្រមព្រហ្មទណ្ឌលេខ ២៤"ម" ចុះថ្ងៃទី ១៤-៦-២០១៣ របស់សាលាដំបូងរាជធានីភ្នំពេញលើចំណុចនៃសេចក្តីសម្រេចទាំងមូល។

-បានឃើញរបាយការណ៍របស់ចៅក្រមសាលាឧទ្ធរណ៍ចុះថ្ងៃទី ២៥-១២-២០១៤។

-បានឃើញសេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការចុះថ្ងៃទី ០៤-៨-២០១៤។

## នាពេលសវនាការសាលាឧទ្ធរណ៍

ចៅក្រមអានរបាយការណ៍រឿង

-ក្រឡាបញ្ជីអានចម្លើយឈ្មោះ [redacted] សុខា

-ឈ្មោះ [redacted] ហ៊ីម បានឆ្លើយថា ក្នុងរឿងនេះខ្លួនមិនបានគំរាមកំហែងគាត់ទេ គឺគាត់បានគំរាមកំហែងខ្លួនឈ្មោះ [redacted] សុខគីម រីឯនៅហាងមង្គលបុរីខ្លួនមិនបានឱ្យគេយកប្រាក់ចំនួន ៨៨ ០០០$ និង ថាគំរាមសម្លាប់នោះទេ ហើយការជួបគ្នានៅហាងមង្គលបុរីហ្នឹងគេហៅខ្លួនទៅជួប ខ្លួនពុំមានអាវុធទេ។ ខ្លួនសំណូមពរសុំឱ្យក្រុមប្រឹក្សាមេត្តាលើកលែងចោទប្រកាន់។

## តំណាងមហាអយ្យការធ្វើសេចក្តីសន្និដ្ឋានថា

១-បណ្តឹងឧទ្ធរណ៍របស់ជនជាប់ចោទឈ្មោះ [redacted] ហ៊ីម ធ្វើឡើងត្រឹមត្រូវតាមទម្រង់ច្បាប់ តាមមាត្រា ៣៧៥,៣៨២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។ ក្នុងរឿងនេះតំណាងមហាអយ្យការជូនក្រុមប្រឹក្សាសម្រេចតាមច្បាប់ចុះ បើផ្អែកតាមចំណាររបស់ឯកឧត្តមអគ្គព្រះរាជអាជ្ញារង [redacted] សុទ្ធី បញ្ជាក់ថាជនជាប់ចោទបាននិយាយថា "បើបាត់ប្លង់ដីអញៗ និងបាញ់សម្លាប់ឱ្យងាប់ទាំងអស់គ្នាអញអស់ទ្រព្យហើយ" នេះគ្រាន់តែជាការបង្កាទេ ព្រោះលុយត្រូវបានចំនួន ១២០ ០០០$ ទើបតែបានចំនួន ១២ ០០០$ ជននេះអស់សង្ឃឹមខ្លាំង គួរតែឱ្យរួចពីបទចោទ។

-មេធាវី [redacted] លឿង ការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] ហ៊ីម បានធ្វើសេចក្តីសន្និដ្ឋានថា ខ្លួនសុំឯកភាពតាមសេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ ហើយអ្វីដែលឈ្មោះ [redacted] ហ៊ីម បានលើកឡើង គឺជាកាតព្វកិច្ចជ្រើសរើសឱ្យឈ្មោះ [redacted] សុខា យកលុយចំនួន ៨៨ ០០០$ មកទៀតដើម្បីបង្គ្រប់ ១០ម៉ឺនដុល្លាអាមេរិក តែបើអ្នកឯងមិនយកប្រាក់មកបង្គ្រប់ទេ ត្រូវយកប្លង់ដីមកឱ្យខ្លួនវិញ។ នេះជាសម្មាភាពជ្ញេប្បវេណីសុទ្ធសាធ, ទាក់ទិនថា ការគំរាមសម្លាប់ ដែលទង្វើមានដល់ទៅបីដងតាមទូរស័ព្ទពីរដង ហើយបើសិនជាគំរាមសម្លាប់មែនហេតុអីក្លាហានហ៊ានមកជួបឃាតករនៅហាងមង្គលបុរីនិយាយគ្នាដោយមិត្តភាព, បើមានរឿងកើតឡើងមែនច្បាស់ជាមានការប្តឹងភ្លាមមិនមែនអូសបន្លាយពេលវេលានោះទេ។ ខ្លួនសំណូមពរសុំឱ្យក្រុមប្រឹក្សាមេត្តាផ្តល់យុត្តិធម៌ និងឱ្យកូនក្តីខ្លួនមានសេរីភាពឡើងវិញ។

-មេធាវី [redacted] សេដ្ឋា ការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] ហ៊ីម បានធ្វើសេចក្តីសន្និដ្ឋានថា អ្នកដែលណាត់កូនក្តីខ្លួនទៅជួបឈ្មោះ [redacted] សុខា ទេ មិនដែលកូនក្តីខ្លួនឈ្មោះ [redacted] ហ៊ីម ជាអ្នកណាត់ឡើយ នេះបញ្ជាក់ឱ្យឃើញថា ជាការរៀបចំដើម្បីចាប់កំហុសលើកូនក្តីរបស់ខ្លួន។ ខ្លួនសំណូមពរសុំឱ្យក្រុមប្រឹក្សាមេត្តាលើកលែងចោទប្រកាន់លើកូនក្តីខ្លួន ព្រោះគាត់រងគ្រោះហើយអស់ប្រាក់ទៀត។

## សភាព្រហ្មទណ្ឌយល់ឃើញថា

១-បណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី ១២-៧-២០១៣ របស់ជនជាប់ចោទឈ្មោះ [redacted] ហ៊ីម ប្តឹងឧទ្ធរណ៍នឹងសាលក្រមព្រហ្មទណ្ឌលេខ ២៤"ម" ចុះថ្ងៃទី ១៤-៦-២០១៣ របស់សាលាដំបូងរាជធានីភ្នំពេញ ធ្វើឡើងក្នុងកំណត់ច្បាប់ តាមមាត្រា ៣៨២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ សភាព្រហ្មទណ្ឌអាចទទួលជំនុំជម្រះបាន។

២-កាលពីថ្ងៃទី ២៥-៩-២០១១ ឈ្មោះ [redacted] ហ៊ីម បានទាក់ទងឈ្មោះ [redacted] សុខា ឱ្យរកខ្ចីប្រាក់ចំនួន ១០ម៉ឺនដុល្លាអាមេរិក ដោយដាក់បញ្ចាំប័ណ្ណដីនៅខេត្តព្រះវិហារ ឈ្មោះ [redacted] សុខា

បានទៅជួបឈ្មោះ [redacted] រតនា ក៏បានព្រមព្រៀងគ្នាឱ្យមុន ១២ ០០០$ ពេលសុរិយោដីដាក់បន្ទុករួច ទើបប្រគល់ប្រាក់ចំនួន ៨៨ ០០០$ គ្រប់ចំនួន។ នៅថ្ងៃទី ៣០-៩-២០១១ ឈ្មោះ [redacted] ហ៊ីម បានគំរាមសម្លាប់តាមទូរស័ព្ទទៅឈ្មោះ [redacted] សុខា និងនិយាយដោយផ្ទាល់ថា បើមិនប្រគល់ប្រាក់ឱ្យគ្រប់ចំនួនទេ។

៣-ជនជាប់ចោទឈ្មោះ [redacted] ហ៊ីម បានឆ្លើយថា ខ្លួនពិតជាបានទូរស័ព្ទជាច្រើនលើកទៅឈ្មោះ [redacted] សុខា រឿងប្រាក់មែន តែពុំបានគំរាមសម្លាប់ទេ ហើយនៅថ្ងៃទី ០១-១០-២០១១ ខ្លួនជួបឈ្មោះ [redacted] សុខា នៅហាងមង្គលបុរី ដោយសារតែខឹងពេក ទើបខ្លួនស្រែក ប៉ុន្តែពុំបានគំរាមឡើយ។

៤-ជនជាប់ចោទ និងដើមបណ្តឹងពិតជាមានទំនាក់ទំនងគ្នា រឿងឱ្យជួយខ្ចីប្រាក់ ហើយភាគីដើមបណ្តឹងបានទទួលប័ណ្ណដីរបស់ជនជាប់ចោទ តាមការព្រមព្រៀង ប៉ុន្តែជនជាប់ចោទរង់ចាំទទួលប្រាក់ដែលខ្ចីនោះយូរពេក ទើបធ្វើឱ្យជនជាប់ចោទមានការខឹង ព្រោះខ្លួនត្រូវការប្រាក់ប្រញាប់ ទើបនៅពេលជនជាប់ចោទជួបជាមួយឈ្មោះ [redacted] សុខា នៅហាងមង្គលបុរី ក៏មានការស្រែកឡូឡាតែម្តង។

៥-អំពើ និងសកម្មភាពរបស់ជនជាប់ចោទឈ្មោះ [redacted] ហ៊ីម មិនមានធាតុផ្សំគ្រប់គ្រាន់ដើម្បីចោទប្រកាន់ ពីបទៈ គំរាមកំហែងថា នឹងសម្លាប់ដោយមានបញ្ជាឱ្យបំពេញលក្ខខណ្ឌអ្វីមួយ, ប្រព្រឹត្តនៅចំណុចរាជធានីភ្នំពេញ កាលពីថ្ងៃទី ៣០-៩-២០១១ និងថ្ងៃទី ០១-១០-២០១១ តាមមាត្រា ២៣៤ នៃក្រមព្រហ្មទណ្ឌឡើយ។ គប្បីសភាព្រហ្មទណ្ឌសម្រេចឱ្យឈ្មោះនេះរួចផុតពីបទចោទប្រកាន់។

៦-សាលក្រមព្រហ្មទណ្ឌលេខ ២៤"ម" ចុះថ្ងៃទី ១៤-៦-២០១៣ របស់សាលាដំបូងរាជធានីភ្នំពេញ សម្រេចសេចក្តីពុំមានលក្ខណៈត្រឹមត្រូវតាមអង្គហេតុ និងអង្គច្បាប់ឡើយ គប្បីបដិសេធចោលរួចសម្រេចឱ្យឈ្មោះ [redacted] ហ៊ីម រួចផុតពីការចោទប្រកាន់ តាមមាត្រា ៤០៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

ហេតុដូច្នេះ

**សម្រេចសេចក្តី**

១-ទទួលបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី ១២-៧-២០១៣ របស់ជនជាប់ចោទឈ្មោះ [redacted] ហ៊ីម ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ និងគតិច្បាប់។

២-បដិសេធសាលក្រមព្រហ្មទណ្ឌលេខ ២៤"ម" ចុះថ្ងៃទី ១៤-៦-២០១៣ របស់សាលាដំបូងរាជធានីភ្នំពេញ ចោល។

៣-ឱ្យឈ្មោះ [redacted] ហ៊ីម ភេទប្រុស អាយុ៤០ឆ្នាំ ជាតិខ្មែរ រួចខ្លួន ពីបទៈ គំរាមកំហែងថានឹងសម្លាប់ដោយមានបញ្ជាឱ្យបំពេញលក្ខខណ្ឌអ្វីមួយ,ប្រព្រឹត្តនៅចំណុចរាជធានីភ្នំពេញ កាលពីថ្ងៃទី ៣០-៩-២០១១ និងថ្ងៃទី ០១-១០-២០១១ តាមមាត្រា ២៣៤ នៃក្រមព្រហ្មទណ្ឌ និងមាត្រា ៤០៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

១៤៧

៤-សាលដីកានេះប្រកាសជាសាធារណៈនៅថ្ងៃទី ០៥-៩-២០១៤ ចំពោះមុខមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ និងជនជាប់ចោទ កំបាំងមុខដើមបណ្តឹងរដ្ឋប្បវេណី។

-បើកផ្លូវប្តឹងតវ៉ាតាមកំណត់ច្បាប់។

**សេចក្តីនេះ ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ទ្រង់ត្រាស់បង្គាប់មកមន្ត្រីទទួលបន្ទុកអនុវត្តសាលដីកា និងស្ថាប័នមានសមត្ថកិច្ចគ្រប់ថ្នាក់ និងកងកំលាំងប្រដាប់អាវុធគ្រប់ថ្នាក់ គ្រប់តំណែង ជួយសហការអនុវត្តសាលដីកានេះឲ្យបានសម្រេច បើមានសំណូមពរត្រឹមត្រូវតាមច្បាប់។**

| ក្រឡាបញ្ជី | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សា |
|---|---|---|
| ហត្ថលេខា | ហត្ថលេខា | ហត្ថលេខា |
| [redacted] | [redacted] [redacted] | [redacted] |

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម។

សាលាឧទ្ធរណ៍ថ្ងៃទី ០១ ខែ 12 ឆ្នាំ ២០១៤

| | |
|---|---|
| បានឃើញ | ក្រឡាបញ្ជី |
| ប្រធានសាលាឧទ្ធរណ៍ | |
| [redacted] | [redacted] |

១៥៨